របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំង

# វ៉ាក់សាំងបង្ការ (ផ្តាសាយ) ជំងឺគ្រុនផ្តាសាយ (បណ្តុះមេរោគ ឬផ្សំមេរោគឡើងវិញ)៖ *តើលោកអ្នកត្រូវការយល់ដឹងអ្វីខ្លះ*

របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំងជាច្រើន អាចមានជាភាសាអេស្ប៉ាញនិងភាសាផ្សេងទៀត។ សូមមើលវិបសាយ www.immunize.org/vis

Hojas de información sobre vacunas están disponibles en español y en muchos otros idiomas. សូមចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវការចាក់វ៉ាក់សាំង?

**វ៉ាក់សាំងជំងឺគ្រុនផ្តាសាយ**អាចការពារ**ជំងឺគ្រុនផ្តាសាយ (ផ្តាសាយ)**។

**ជំងឺគ្រុនផ្តាសាយ**គឺជាជំងឺឆ្លងដែលរីករាលដាលនៅជុំវិញសហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ តាមធម្មតាកើតឡើងនៅចន្លោះខែតុលា និងឧសភា។ នរណាម្នាក់អាចកើតជំងឺគ្រុនផ្តាសាយ ប៉ុន្តែវាមានគ្រោះថ្នាក់ច្រើនជាងនេះចំពោះមនុស្សមួយចំនួន។ ទារក និងកូនក្មេង មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ អ្នកមានផ្ទៃពោះ និងអ្នកដែលមានបញ្ហាសុខភាពមួយចំនួន ឬប្រព័ន្ធភាពស៊ាំជំងឺចុះខ្សោយ មានហានិភ័យនៃផលវិបាកជំងឺផ្តាសាយខ្ពស់បំផុត។

ជំងឺរលាកសួត រលាកទងសួត រលាកប្រហោងឆ្អឹង និងការឆ្លងមេរោគត្រចៀក គឺជាឧទាហរណ៍នៃផលវិបាកដែលទាក់ទងនឹងជំងឺផ្តាសាយ។ ប្រសិនបើលោកអ្នកមានបញ្ហាសុខភាព ដូចជាជំងឺបេះដូង មហារីក ឬជំងឺទឹកនោមផ្អែម ជំងឺគ្រុនផ្តាសាយអាចធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ។

ជំងឺផ្តាសាយអាចបណ្តាលឱ្យមានគ្រុនក្តៅខ្លួន និងគ្រុនរងា ឈឺបំពង់ក ឈឺសាច់ដុំ អស់កម្លាំង ក្អក ឈឺក្បាល និងហៀរសំបោរ ឬតឹងច្រមុះ។ មនុស្សមួយចំនួនអាចក្អួត និងរាគ ទោះបីជាជំងឺនេះកើតលើកុមារច្រើនជាងមនុស្សពេញវ័យក៏ដោយ។

គិតជាមធ្យមក្នុងមួយឆ្នាំមាន**មនុស្សរាប់ពាន់នាក់នៅសហរដ្ឋអាមេរិកបានស្លាប់ដោយសារជំងឺគ្រុនផ្តាសាយ** ហើយមានមនុស្សជាច្រើននាក់ទៀតកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយការពារពីការមានជំងឺរាប់លាននាក់ និងការទៅជួបគ្រូពេទ្យដែលទាក់ទងនឹងជំងឺផ្តាសាយជារៀងរាល់ឆ្នាំ។

## 2. វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយ

មជ្ឈមណ្ឌល CDC ណែនាំមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ត្រូវចាក់វ៉ាក់សាំងនៅគ្រប់រដូវកាលជំងឺគ្រុនផ្តាសាយ។ **ក្មេងអាយុពី 6 ខែដល់ 8 ឆ្នាំ** អាចត្រូវការ 2 ដូស នៅអំឡុងពេលរដូវកាលជំងឺគ្រុនផ្តាសាយនីមួយៗ។ **អ្នកផ្សេងទៀត**ត្រូវការតែ 1 ដូសក្នុងមួយរដូវកាលជំងឺគ្រុនផ្តាសាយ។

វាត្រូវចំណាយពេលប្រហែល 2 សប្តាហ៍សម្រាប់ការបង្កើតឱ្យមានការការពារបន្ទាប់ពីការចាក់វ៉ាក់សាំង។

មានមេរោគផ្តាសាយជាច្រើន ហើយវាតែងតែផ្លាស់ប្តូរ។ ជារៀងរាល់ឆ្នាំ ក់សាំងជំងឺផ្តាសាយថ្មីត្រូវបានបង្កើតឡើងដើម្បីការពារប្រឆាំងនឹងជំងឺគ្រុនផ្តាសាយ ដែលគេជឿជាក់ថាទំនងជាបង្កជំងឺឆ្លងនៅរដូវកាលជំងឺគ្រុនផ្តាសាយនាពេលខាងមុខ។

ទោះបីជាវ៉ាក់សាំងមិនត្រូវគ្នានឹងមេរោគទាំងនេះដោយជាក់លាក់ក៏ដោយ ក៏វានៅតែអាចផ្តល់ការការពារមួយចំនួនផងដែរ។

វ៉ាក់សាំងជំងឺគ្រុនផ្តាសាយ**មិនបង្កផ្តាសាយទេ**។

វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយអាចចាក់នៅពេលដំណាលគ្នានឹងវ៉ាក់សាំងផ្សេងទៀតបាន។

## 3. សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

សូមប្រាប់អ្នកផ្តល់សេវាចាក់វ៉ាក់សាំងបង្ការរបស់អ្នក ប្រសិនបើលោកអ្នកចាក់វ៉ាក់សាំងបង្ការ៖

- មាន**ប្រតិកម្មអាល់ឡែហ្ស៊ី បន្ទាប់ពីការចាក់វ៉ាក់សាំងដូសបង្ការជំងឺគ្រុនផ្តាសាយពីមុន** ឬមាន**អាល់ឡែហ្ស៊ីធ្ងន់ធ្ងរណាមួយដែលគំរាមកំហែងដល់អាយុជីវិត**
- ធ្លាប់មាន**រោគសញ្ញាហ្គីលឡេន-បារេ** (Guillain-Barré Syndrome) (គេហៅផងដែរថា "GBS")

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក អាចសម្រេចចិត្តពន្យាពេលការចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយរហូតដល់ការទៅជួបពិនិត្យនាពេលខាងមុខ។

វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយអាចចាក់បានគ្រប់ពេលនៅអំឡុងពេលមានផ្ទៃពោះ។ អ្នកដែលមានផ្ទៃពោះ ឬនឹងមានផ្ទៃពោះនៅអំឡុងរដូវកាលជំងឺគ្រុនផ្តាសាយគួរចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយដែលមានបណ្តុះមេរោគ។

អ្នកដែលមានជំងឺកម្រិតស្រាល ដូចជាផ្តាសាយ អាចចាក់វ៉ាក់សាំងបាន។ អ្នកដែលឈឺកម្រិតមធ្យម ឬធ្ងន់ធ្ងរ តាមធម្មតាគួររង់ចាំរហូតដល់ពួកគេជាសះស្បើយឡើងវិញ មុនពេលចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយ។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក អាចផ្តល់ជូនលោកអ្នកនូវព័ត៌មានបន្ថែម។



ក្រសួងសុខាភិបាល និងសេវាពលរដ្ឋនៃសហរដ្ឋអាមេរិក
មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ

## 4. ហានិភ័យនៃប្រតិកម្មវ៉ាក់សាំងបង្ការ

- ឈឺ ឡើងក្រហម និងហើមនៅកន្លែងចាក់ថ្នាំ គ្រុនក្តៅខ្លួន ឈឺសាច់ដុំ និងឈឺក្បាល អាចកើតឡើងបន្ទាប់ពីចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយ។
- ប្រហែលជាអាចមានហានិភ័យកើនឡើងតិចតួចបំផុតនៃរោគសញ្ញា Guillain-Barré (GBS) បន្ទាប់ពីការចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយដែលមានបណ្តុះមេរោគ (ការចាក់វ៉ាក់សាំងជំងឺផ្តាសាយ)។

កុមារតូចៗដែលចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយរួមជាមួយនឹងវ៉ាក់សាំងការពារជំងឺរលាកសួត (PCV13) និង/ឬ វ៉ាក់សាំង DTaP ក្នុងពេលតែមួយអាចទំនងភាគច្រើនមានការប្រកាច់ដែលបណ្តាលមកពីគ្រុនក្តៅខ្លួន។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើកុមារដែលចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធ្លាប់ប្រកាច់។

ពេលខ្លះមនុស្សដួលសន្លប់បន្ទាប់ពីដំណើរការផ្នែកវេជ្ជសាស្ត្រ រួមទាំងការចាក់វ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវារបស់អ្នក ប្រសិនបើលោកអ្នកមានអារម្មណ៍វិលមុខ ឬមានការផ្លាស់ប្តូរការមើលឃើញ ឬឮសូរ សម្លេងនៅក្នុងត្រចៀក។

ដូចគ្នាទៅនឹងថ្នាំណាមួយផងដែរ វ៉ាក់សាំងមានឱកាសតិចតួចណាស់ដែលបង្កឱ្យមានប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេងទៀត ឬស្លាប់។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាល់ឡែហ្ស៊ីអាចកើតឡើងបន្ទាប់ពីលោកអ្នកចាក់វ៉ាក់សាំងបង្ការចាកចេញពីគ្លីនិក។ ប្រសិនបើលោកអ្នកឃើញសញ្ញាប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរ (កន្ទួលលើស្បែក ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមហៅទូរស័ព្ទលេខ **9-1-1** ហើយនាំអ្នកជំងឺទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

សម្រាប់សញ្ញាផ្សេងទៀតដែលទាក់ទងនឹងលោកអ្នក សូមហៅទូរស័ព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

សូមរាយការណ៍ប្រតិកម្មមិនល្អទៅប្រព័ន្ធរាយការណ៍ពីចំណុចមិនល្អនៃវ៉ាក់សាំង (VAERS)។ តាមធម្មតាអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកនឹងដាក់របាយការណ៍នេះ ឬលោកអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលមើលវិបសាយ VAERS តាម www.vaers.hhs.gov ឬហៅទូរស័ព្ទលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ VAERS គឺសម្រាប់រាយការណ៍ពីប្រតិកម្មតែប៉ុណ្ណោះ ហើយសមាជិកនៃបុគ្គលិក VAERS មិនផ្តល់ជូន ការណែនាំផ្នែកវេជ្ជសាស្ត្រទេ។*

## 6. កម្មវិធីសំណងរបួសស្នាមដោយវ៉ាក់សាំងបង្ការថ្នាក់ជាតិ

កម្មវិធីសំណងរបួសស្នាមដោយវ៉ាក់សាំងបង្ការថ្នាក់ជាតិ (VICP) គឺជាកម្មវិធីរបស់សហព័ន្ធដែលបានបង្កើតឡើង ដើម្បីផ្តល់ជូនសំណងដល់ប្រជាពលរដ្ឋដែលអាចរងរបួសដោយសារវ៉ាក់សាំងមួយចំនួន។ បណ្តឹងទាមទារទាក់ទងនឹងរបួស ឬការស្លាប់ដោយសារការចាក់វ៉ាក់សាំង មានពេលកំណត់សម្រាប់ការដាក់ឯកសារ ដែលអាចមានរយៈពេលខ្លីរហូតដល់ពីរឆ្នាំ។ សូមចូលទៅគេហទំព័រ VICP តាម www.hrsa.gov/vaccinecompensation ឬហៅទូរស័ព្ទលេខ **1-800-338-2382** ដើម្បីស្វែងយល់អំពីកម្មវិធី និងការដាក់ឯកសារបណ្តឹងទាមទារ។

## 7. តើខ្ញុំអាចស្វែងយល់បន្ថែមដោយរបៀបណា?

- សូមសាកសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមហៅទូរស័ព្ទទៅនាយកដ្ឋានសុខាភិបាលនៅមូលដ្ឋាន ឬរដ្ឋរបស់អ្នក។
- សូមចូលទៅគេហទំព័ររដ្ឋបាលចំណីអាហារនិងឱសថ (FDA) សម្រាប់ការបញ្ចូលកញ្ចប់វ៉ាក់សាំង និងព័ត៌មានបន្ថែមតាម www.fda.gov/vaccines-blood-biologics/vaccines.
- សូមទាក់ទងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ (CDC)៖
  -សូមហៅទូរស័ព្ទលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  -សូមចូលមើលវិបសាយ CDC តាម www.cdc.gov/flu.